**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ * MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១១៥៩ សហវ-ទ

លិខិតចូល
ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# ប្រកាសណែនាំ
# ស្តីពី
# ការបិទបញ្ជីចំណូល-ចំណាយ និង
# ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៧

- យោងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- យោងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។

ដោយឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ( មាត្រា ៤ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេសដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយនិងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧ ប្រព្រឹត្តទៅបានត្រឹមត្រូវ និង ទាន់ពេលវេលា ដូចតទៅនេះ :

## I-<u>អំពីការបិទបញ្ជីចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧</u>

### ក-<u>អំពីចំណូលថវិការដ្ឋ</u>

ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធដកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬមួយពន្យារពេលបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ ( ភាគទី III និង មាត្រា១០៦ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ជាកំហិត** ។

### ខ-<u>អំពីចំណាយថវិការដ្ឋ</u>

ការបិទបញ្ជីចំណាយ ( មាត្រា ១០៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយ និង ពេលវេលាដូចតទៅ :

* **ទិដ្ឋាការនៃការសន្យាចំណាយ** ក្រៅពីចំណាយបៀវត្ស និង ចំណាយសំរាប់គោលនយោបាយសង្គមកិច្ច **មិនអាចអនុវត្តក្រោយថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បានទេ** ( មាត្រា ១០៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ) លើកលែងក្នុងករណីមាន**ចំណាយចាំបាច់មិនអាចខានបាន និង មានឥណទានថវិកាសល់ទំនេរ** ហើយទិដ្ឋាការនេះត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( មាត្រា ២០ នៃអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) តែក៏**មិនឱ្យហួសពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៧ ដែរ** ។

* **រាល់ការសន្យាចំណាយដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រូវបានបដិសេធចោល ហើយត្រូវស្នើសុំធានាចំណាយជាថ្មី ដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់** ( មាត្រា ១០៩ នៃ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។

* រតនាគារជាតិ និងរតនាគារខេត្ត-ក្រុង **ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧** លើកលែងអាណត្តិប្រាក់បៀវត្ស និង ប្រាក់គោលនយោបាយសង្គមកិច្ច និង អាណត្តិនិយ័តកម្ម ( មាត្រា១១១ អនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥) ។ ដូច្នេះ ក្រសួង-ស្ថាប័នត្រូវប្រមូលសក្ខីប័ត្រ និង លិខិតយុត្តិការដែលបញ្ជាក់ពីសេវាដែលបានធ្វើរួច ដើម្បីរៀបចំអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី **២៥ ខែ ធ្នូ**

**ឆ្នាំ ២០០៧** ។ ដោយឡែកមន្ទីរជំនាញខេត្ត-ក្រុង ត្រូវបញ្ជូនអាណត្តិបើកប្រាក់ដែលបានឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ **ទៅអភិបាល ខេត្ត-ក្រុងពិនិត្យចុះហត្ថលេខា ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៧** ។

### គ-អំពីចំណាយរដ្ឋទេយ្យបុរេប្រទាន និង ថវិកាបុរេប្រទាន

* **រដ្ឋទេយ្យករបុរេប្រទានត្រូវប្រមែប្រមូលលិខិតយុត្តិការចំណាយ ដើម្បីធ្វើអាណត្តិនិយ័តកម្ម(ទូទាត់) យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ** ដោយគិតចាប់ពីកាលបរិច្ឆេទដកសាច់ប្រាក់ពីរតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង (មាត្រា ៦៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) លើកលែងតែក្នុងខែធ្នូនៃឆ្នាំ រតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង **ត្រូវបញ្ឈប់ការដកសាច់ប្រាក់ចុងក្រោយបង្អស់ពីគណនីរដ្ឋទេយ្យបុរេប្រទាន នៅម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៧** ។ ក្នុងរយៈពេលពីថ្ងៃទី ១១ ដល់ ថ្ងៃទី **២៥ ខែ ធ្នូ ឆ្នាំ ២០០៧** រដ្ឋទេយ្យករបុរេប្រទាន ត្រូវរូតរះប្រមូលឯកសារ និង លិខិតយុត្តិការចំណាយ ដើម្បីធ្វើអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការ រួចបញ្ជូនទៅរតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង **ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧** ជាកំហិត ។

* **ថវិកាបុរេប្រទាន** គឺជាការបើកផ្តល់ចំណាយមុនដែរ ក្នុងករណីមានការចាំបាច់បន្ទាន់ ដូច្នេះការផ្តល់ថវិកាបុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយការទូទាត់ថវិកាបុរេប្រទាននេះ ក៏ត្រូវរូតរះប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០០៧** ដោយគិតរួមទាំងចំណាយថវិកាបុរេប្រទានជារូបិយប័ណ្ណអន្តរជាតិ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្តល់ជូនតាមរយៈមូលប្បទានប័ត្រ ។ **ក្នុងករណីប្រាក់បុរេប្រទាន ឆ្នាំ ២០០៧ មិនត្រូវបានធ្វើការទូទាត់ឱ្យជ្រះស្រឡះទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងកាត់ទុកឥណទានថវិកាពាក់ព័ន្ធក្នុងក្របខ័ណ្ឌថវិកាឆ្នាំ ២០០៨ មុននឹងផ្តល់ធានាចំណាយសំរាប់ឆ្នាំ ២០០៨ ។**

ក្នុងករណីមានការខ្វះខាតឥណទានថវិកាសំរាប់ធ្វើការទូទាត់រដ្ឋទេយ្យបុរេប្រទាន ឬ បុរេប្រទានរដ្ឋទេយ្យករ ត្រូវរាយការណ៍ជាបន្ទាន់ទៅអាណាប័ក ដើម្បីមានវិធានការតាមការជាក់ស្តែង ជាអាទិ៍ :

- លើកសំណើសុំនិយ័តភាពថវិកាផ្ទៃក្នុងដែលសល់ទំនេរមកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវធ្វើអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុនៗផងដែរ ។
- កាត់បន្ថយ ឬ ផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួន ដែលមិនសូវចាំបាច់ សំដៅធ្វើការជំរះបញ្ជីចំណាយថវិការដ្ឋទេយ្យបុរេប្រទាន ឬ បុរេប្រទាន ឱ្យបានជ្រះស្រឡះ ។

### ឃ-អំពីចលនាឥណទាន

ការធ្វើ**និយ័តភាពថវិកា**ផ្ទៃក្នុងជំពូកសំរាប់ការទូទាត់ចំណាយចាំបាច់ ឬ ទូទាត់រដ្ឋទេយ្យបុរេប្រទាន ឬ ទូទាត់បុរេប្រទាន **ត្រូវបញ្ឈប់នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧** ។ ដូច្នេះក្រសួង-ស្ថាប័ន និង មន្ទីរជំនាញតាមខេត្ត-

ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំនិយ័តភាពឥណទាន មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **យ៉ាងយូរត្រឹមថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧** ។

**១-កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារ**

កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវ**បន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨** ( មាត្រា ១១ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។ កិច្ចប្រតិបត្តិការនេះ ត្រូវពិនិត្យកត់ត្រាជាលេខនាបន្ថែម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលទាក់ទងទៅនឹង :

* ការកត់ត្រាជាស្ថាពរនៃចំណូល ឬ ចំណាយដែលបានពិនិត្យកត់ត្រាជាលេខនាមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
* អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យបុរេប្រទាន និងបុរេប្រទាន មុនថ្ងៃទី ៣១ ខែ ធ្នូ ។
* ការកែតម្រូវលេខនាខុស ។
* កិច្ចប្រតិបត្តិការប្រមូលកិច្ចការគណនេយ្យករនៃអង្គភាពរដ្ឋបាលហិរញ្ញវត្ថុ និង គណនេយ្យកររងនៃរតនាគារខេត្ត-ក្រុង ។

**២- កិច្ចប្រតិបត្តិការថវិកាឆ្នាំ ២០០៨**

១- ក្នុងករណីមានភាពប្រញាប់លើឥណទាននៃឆ្នាំបន្ទាប់ (២០០៨) ក្នុងអំឡុងខែ ធ្នូ ឆ្នាំ ២០០៧ អនុញ្ញាត អោយក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត-ក្រុង ស្នើសុំធានាចំណាយថវិកា សំរាប់ឆ្នាំ ២០០៨ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់មន្ទីរជំនាញខេត្ត-ក្រុង ដោយឈរលើមូលដ្ឋាន ១/១២ នៃឥណទានប្រចាំឆ្នាំ ២០០៧ ។

២- គំរោងស្នើសុំធានាចំណាយត្រូវធ្វើឡើងចំពោះតែមុខទំនិញ សេវា ឬ ការជួសជុលថែទាំទាំងឡាយណា ដែលមានតំរូវការចំណាយថវិកាច្រើន និង មានតំរូវការជាបន្ទាន់នូវការផ្គត់ផ្គង់ទំនិញ សេវា ឬ ការជួសជុលថែទាំ នៅដើមឆ្នាំ ២០០៨ ។

៣- ចំពោះការធានាចំណាយថវិកាជាបន្តបន្ទាប់ទៀត ដែលត្រូវអនុវត្តក្នុងអំឡុងឆ្នាំថវិកា នឹងត្រូវផ្តល់ជូន ក្រោយពីការតម្រឹមផ្ទៀងផ្ទាត់ជាមួយឥណទានថវិកា ដែលត្រូវបានអនុម័តយល់ព្រមដោយអង្គការនីតិបញ្ញត្តិ ។

៤- ចាប់ពីថ្ងៃទី ០១ ខែ **មករា ឆ្នាំ ២០០៨** តទៅ រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋ ឆ្នាំថ្មី **ត្រូវកត់ត្រាចូលក្នុងគណនីថវិការដ្ឋឆ្នាំ ២០០៨** ។ ដោយឡែក ចំពោះប្រាក់បៀវត្សដែលនៅសល់ពីឆ្នាំចាស់ (២០០៧) ហើយយកមកបង់ចូលនៅក្នុងឆ្នាំ ២០០៨ ត្រូវចាត់ទុកថាជាសំណេះចំណាយ ដោយកត់ត្រាបន្ថយ លើខ្ទង់ចំណាយ ដែលមានការពាក់ព័ន្ធ ។

៥- រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាឆ្នាំ ២០០៨ ត្រូវផ្អែកលើកម្មវិធីចំណូល-ចំណាយ ប្រចាំខែ និង ត្រីមាស ដែលក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំ និង ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ក្នុងរយៈពេល ០២ សប្តាហ៍ ក្រោយពីច្បាប់ថវិកាត្រូវបានអនុម័ត ។

## II-ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧

ការបូកសរុបសម្រេចអំពីការអនុវត្តថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧ ត្រូវដំណើរការដូចតទៅ :

* ចាប់ពីថ្ងៃទី **០១ ខែ កុម្ភៈ ឆ្នាំ ២០០៨** រតនាគារជាតិ ត្រូវដំណើរការបូកសរុបកិច្ចប្រតិបត្តិការរតនាគារទូទាំងប្រទេស អំពីការអនុវត្តចំណូល-ចំណាយថវិកាឆ្នាំ ២០០៧ ព្រមទាំងធ្វើតារាងតុល្យភាពគណនីជាស្ថាពរ **យ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨** ។

* ចាប់ពីថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០០៨** គ្រប់មន្ទីរជំនាញខេត្ត-ក្រុង ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយរបស់អង្គភាពខ្លួនឱ្យបានត្រូវគ្នាជាមួយរតនាគារខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួន រួចផ្ញើមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសាមី **ឱ្យបានមុនថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨** ។

* មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចបូកសរុបអនុវត្តចំណូល-ចំណាយ របស់មន្ទីរជំនាញនៅខេត្ត-ក្រុងដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( រតនាគារជាតិ និង នាយកដ្ឋានថវិកា ) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ជាកំហិត** ។

* ចំពោះក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាលត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយថវិការបស់ខ្លួនជាមួយរតនាគារជាតិ នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ (ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស) និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីឱ្យបានត្រូវគ្នា ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិការបស់ក្រសួង-ស្ថាប័នខ្លួន ដោយមានបញ្ចូលចំណូល-ចំណាយថវិការបស់មន្ទីរជំនាញនានាក្រោមឱវាទនៅតាមខេត្ត-ក្រុង រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( រតនាគារជាតិ និង នាយកដ្ឋានថវិកា ) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ជាកំហិត** ។

* ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ក្រសួង-ស្ថាប័ន ត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តជាមួយអង្គភាពគ្រប់គ្រងគំរោងរបស់ក្រសួង-ស្ថាប័ននីមួយៗ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណាយវិនិយោគប្រចាំឆ្នាំ ២០០៧ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និង នាយកដ្ឋានថវិកា) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ជាកំហិត** ។

ក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួន ទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ ឱ្យបានតាមកាលកំណត់ខាងលើជាកំហិត ដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុបរៀបចំសេចក្តីព្រាង

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និង ស្ថាប័ននីតិបញ្ញត្តិអនុម័ត ឱ្យបានទាន់ពេលវេលា ។

ក្នុងករណីក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុណា ផ្ញើរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួនមិនបានទាន់ពេលវេលាកំណត់ខាងលើទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្អែកតាមតួលេខរបាយការណ៍បូកសរុបរបស់រតនាគារជាតិជាផ្លូវការ ។

គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល រតនាគារជាតិ រតនាគារខេត្ត-ក្រុង មន្ទីរជំនាញខេត្ត-ក្រុង និង នាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូនៈ**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អាជ្ញាធរសវនកម្មជាតិ
  (ដើម្បីជូនជ្រាបជាព័ត៌មាន)
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- -គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល
- -នាយកដ្ឋានហិរញ្ញកិច្ច
- -នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ
- -នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- -នាយកដ្ឋាននីតិកម្ម
- -នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ
- -នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ
- -នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ
- -នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- -រតនាគារជាតិ
- -គ្រប់អភិបាលខេត្ត-ក្រុង
- -មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង
- -រតនាគារខេត្ត-ក្រុង
- -គ្រប់មន្ទីរជំនាញតាមខេត្ត-ក្រុង
  (ដើម្បីអនុវត្ត)
- -ឯកសារនិងកាលប្បវត្តិ

ក្រសួង:....................

## តារាងសរុបចំណូលថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ១

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | - |
| | | | I -ថ្នាក់រដ្ឋបាលកណ្តាល | | | | |
| | | | II-ថ្នាក់មន្ទីរជំនាញខេត្ត-ក្រុង | | | | |
| | | | សរុបរួម | | | | |

| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|---|
| ប្រធានធនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

ក្រសួង:.....................

## តារាងសរុបចំណាយថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ២

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | ឥណទានថ្មី | អនុវត្តជាក់ស្តែង | សមមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | + | - | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦=៥/៤ | |
| | | | I- ថវិការដ្ឋបាលកណ្តាល<br>១. សរុបចំណាយចរន្ត<br>២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស<br>II -ថវិកាមន្ទីរជំនាញខេត្ត-ក្រុង<br>១. សរុបចំណាយចរន្ត<br>២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |
| | | | សរុបរួម<br>១. សរុបចំណាយចរន្ត<br>២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |

| ហត្ថលេខានិងត្រា<br>ប្រធានធនាគារជាតិ | ហត្ថលេខានិងត្រា<br>រដ្ឋមន្ត្រី | ហត្ថលេខា<br>ប្រធានគណនេយ្យ | ហត្ថលេខា<br>អ្នកធ្វើតារាង |
|---|---|---|---|

ក្រសួង:.....................

• តារាងសរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ៣

ឯកតា: ពាន់ដុល្លារអាមេរិក

| លេខគំរោង | ឈ្មោះគំរោង | ប្រភេទគំរោង | ប្រភពជំនួយ | ប្រភេទជំនួយ | រយៈពេលអនុវត្តគំរោង | តំលៃគំរោង | គំរោងឆ្នាំ ២០០៧ | អនុវត្តជាក់ស្តែងឆ្នាំ ២០០៧ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបរួម | | | | | | | | |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខ
ប្រធានអង្គភាពគ្រប់គ្រងគំរោង

ហត្ថលេខា
ប្រធានគណនេយ្យ

ហត្ថលេខា
អ្នកធ្វើតារាង

ខេត្ត-ក្រុង:...................

មន្ទីរ:........................

## តារាងសរុបចំណូលថវិកាជាតិ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ៤

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | | | | | |
| | | | សរុបរួម | | | | |

| | | | | |
|---|---|---|---|---|
| ហត្ថលេខានិងត្រា<br>ប្រធានរតនាគារខេត្ត-ក្រុង | ហត្ថលេខានិងត្រា<br>អភិបាលខេត្ត-ក្រុង | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ហត្ថលេខា<br>ប្រធានគណនេយ្យ | ហត្ថលេខា<br>អ្នកធ្វើតារាង |

ខេត្ត-ក្រុង:...................

មន្ទីរ:.........................

## តារាងសរុបចំណាយថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ៥

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | ឥណទានថ្មី | អនុវត្តជាក់ស្តែង | សមមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | + | - | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦=៥/៤ | |
| | | | ១. សរុបចំណាយចរន្ត | | | | | | | |
| | | | ២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |
| | | | សរុបរួម | | | | | | | |

ហត្ថលេខានិងត្រា<br>ប្រធានរតនាគារខេត្ត-ក្រុង

ហត្ថលេខានិងត្រា<br>អភិបាលខេត្ត-ក្រុង

ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា<br>ប្រធានគណនេយ្យ

ហត្ថលេខា<br>អ្នកធ្វើតារាង